ORGANIZERS

Debra Fram and Eric Schwartz

DONOR

ULS

LANDSCAPE SPONSOR

# ម្លប់សហគមន៍

គម្រោងជំនាន់នៃភាពច្នៃប្រឌិត
«ម្លប់សហគមន៍» ដំណើរការទៅបានក្រោមកិច្ចសហការជាមួយអង្គការសិល្បៈខ្មែរអមតៈ

«ម្លប់សហគមន៍» គឺជាគម្រោងធ្វើឡើងនៅទីតាំងជាក់លាក់មួយ ដែលដំណើរការនៅលើចំណុចប្រសព្វរវាងសិល្បៈ ស្ថាបត្យកម្ម និងសហគមន៍។ នេះជាការបង្កើតស្នាដៃផ្នែកស្ថាបត្យកម្ម នៅអង្គការខ្មែរសិល្បៈអមតៈតែម្តង ដែលជាទីតាំងសម្រាប់ការជួបជុំសហគមន៍ ការរៀបចំព្រឹត្តិការណ៍ និងការផ្តល់ជាលំហសុវត្ថិភាពមួយ ក្នុងការបញ្ចេញមតិផ្ទាល់ខ្លួននានា។

ការរចនាសម្រាប់គម្រោង «ម្លប់សហគមន៍» នឹងត្រូវជ្រើសចេញពីពាក្យស្នើសុំពោរពេញដោយភាពច្នៃប្រឌិតដែលក្រុមយុវជនកម្ពុជាបញ្ជូនមក។ ក្រុមយុវជនអាចមានសមាជិកដែលមានជំនាញផ្សេងៗគ្នាដូចជា ស្ថាបត្យកម្ម សិល្បៈ និងការរចនា។ យើងរំពឹងចង់ឃើញកិច្ចសហការក្នុងចំណោមសមាជិកក្រុមដែលអាចបញ្ចេញសក្តានុពលខ្ពស់បំផុតនៅក្នុងជំនាញ និងគំនិតផ្សេងៗរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃការរចនាសម្រាប់គម្រោងនេះ។

ចំណុចស្នូលនៃគម្រោងនេះ គឺគំនិតនៃការផ្សារភ្ជាប់គ្នាតាមរយៈការចូលរួមយ៉ាងសកម្មរបស់សហគមន៍។ គំនិតខាងលើយើងទុកជាគោលការណ៍ណែនាំ ដំណើរការ គឺមានសារៈសំខាន់ដូចលទ្ធផលសម្រេចដូច្នេះដែរ។ ក្រុមរចនាជ័យលាភីត្រូវបង្កើតយុទ្ធសាស្ត្រ ដើម្បីភ្ជាប់សហគមន៍ទៅក្នុងគំនិតនៃការរចនារបស់គេឱ្យមានប្រសិទ្ធភាព។ ពួកគេត្រូវតែរំលេចសារៈសំខាន់នៃការបង្កើតទីតាំងដែលញ៉ាំងឱ្យមានកិច្ចសហការនានា។ ពួកគេអាចពិចារណានូវវិធីសាស្ត្រមួយចំនួនខាងក្រោមនេះ ដើម្បីញ៉ាំងការចូលរួមរបស់សហគមន៍៖

- អញ្ជើញសិល្បករដែលស្ថិតក្នុងបណ្តាញសិល្បករសិល្បៈអង្គការសិល្បៈខ្មែរអមតៈ ឱ្យចូលរួមក្នុងដំណើរការរចនា។
- ធ្វើការជាមួយសិល្បករដែលស្ថិតក្នុងបណ្តាញសិល្បករសិល្បៈអង្គការសិល្បៈខ្មែរអមតៈ ដើម្បីឱ្យពួកគាត់ចូលរួមចំណែកលើផ្នែកខ្លះនៃរចនាសម្ព័ន្ធ ឬ គ្រោងសំណង់ ។
- បញ្ចូលគំនិតរចនាដែលបង្កើតទំនាក់ទំនងគ្នាទៅវិញទៅមក ដោយលើកទឹកចិត្តអ្នកមកទស្សនាឱ្យមានការចូលរួមជាមួយនឹងរចនាសម្ព័ន្ធឬ គ្រោងសំណង់នោះ។
- ឬបង្កើតគំនិតខ្លួនអ្នកផ្ទាល់

នេះគឺជាឱកាសដ៏ពិសេសសម្រាប់យុវជនដែលពោរពេញដោយគំនិតច្នៃប្រតិដ្ឋក្នុងប្រទេសកម្ពុជា ក្នុងការបង្កើតទីតាំងមួយដែលរំលេចពីគំនិតនវានុវត្តន៍សង្គម ដោយផ្តល់នូវឱកាសរចនា ដ៏គួរឱ្យរំភើបមួយ ដល់សមាជិកពាក់ព័ន្ធនឹងគម្រោង។ លើសពីនេះទៅទៀត គម្រោងនេះជាឱកាសមួយសម្រាប់អ្នកច្នៃប្រតិដ្ឋជំនាន់ថ្មី ដើម្បីធ្វើការជាមួយអ្នកជំនាញផ្នែកសិល្បៈ ស្ថាបត្យកម្ម និងការអភិវឌ្ឍសហគមន៍។

## **តើអ្នកឈ្នះជ័យលាភីនឹងទទួលបានអ្វី?**

- ប្លង់រចនារបស់ក្រុមជ័យលាភីនឹងត្រូវដំឡើងនៅទីតាំងអង្គការសិល្បៈខ្មែរអមតៈនៅចុងឆ្នាំនេះ ហើយការបើកសម្ពោធជាសាធារណៈនឹងប្រព្រឹត្តឡើងនៅអំឡុងខែធ្នូ។
- រង្វាន់ជាទឹកប្រាក់
  - ក្រុមជាប់ជម្រើសចំនួន ៥ នឹងទទួលបានរង្វាន់ទឹកប្រាក់ ២៥០ ដុល្លារ
  - ក្រុមរចនាជ័យលាភីនឹងទទួលបានរង្វាន់ទឹកប្រាក់បន្ថែមចំនួន ៧៥០ ដុល្លារ
- ការបង្វឹកណែនាំ
  - ក្រុមជាប់ជម្រើសចំនួន ៥ នឹងទទួលបានការបង្វឹកពីអ្នកជំនាញជាច្រើនរូប ក្នុងការរៀបចំបទបង្ហាញសម្រេចរបស់ពួកគេ។
  - ក្រុមរចនាជ័យលាភីនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារជំនាន់នៃភាពច្នៃប្រឌិត និងអ្នកសាងសង់អាជីព ដើម្បីដំឡើងទីតាំងម្លប់ថ្មីមួយ ក៏ដូចជាទទួលបានការគាំទ្រលើបញ្ហាបច្ចេកទេសនានា។
- ទឹកប្រាក់ចំនួន ៦០០០ ដុល្លារ សម្រាប់ការចំណាយលើថ្លៃសម្ភារៈ កម្លាំង និងជំនួយគាំទ្រវិស្វកម្ម
- ក្រុមរចនាជ័យលាភីនឹងធ្វើការរួមគ្នាទៅលើការរចនាស្ថាបត្យកម្មទេសភាព ឱ្យត្រូវបរិវេណជាមួយនឹង Urban Living Solutions ដែលជាអ្នកដែលផ្តល់ការជួយគាំទ្រដល់គម្រោងនេះ។

## **តើយើងរំពឹងចង់ឃើញអ្វី?**

យើងរំពឹងចង់ឃើញការរចនាដែលធ្វើឱ្យយើងភ្ញាក់ផ្អើល ដោយសារសោភ័ណភាព និងភាពច្នៃប្រតិដ្ឋដែលបង្កប់នៅក្នុងនោះ។ ប៉ុន្តែ អ្វីដែលសំខាន់បំផុត គឺយើងចង់ដឹងថា គម្រោងនោះអាចផ្សារភ្ជាប់ទៅនឹងសហគមន៍ដោយរបៀបណា។ តាមរយៈឈ្មោះ «ម្លប់សហគមន៍» វាគឺជារឿងសំខាន់ណាស់ដែលការរចនា និងរចនាសម្ព័ន្ធទីតាំងមានទំនាក់ទំនងជិតស្និទ្ធទៅនឹងបរិយាកាសជុំវិញ ក៏ដូចជាសហគមន៍ដែលប្រើប្រាស់ទីតាំងនោះ នាពេលខាងមុខ។ យើងចង់ឱ្យទីតាំងម្លប់ដំឡើងថ្មីនេះ ជំរុញឱ្យមនុស្សមានអារម្មណ៍ផ្សារភ្ជាប់រវាងគ្នានឹងគ្នាកាន់តែជិតស្និទ្ធ។

**អ្វីដែលអ្នកគួរពិចារណា៖**

- ការរចនាគឺត្រូវតែឆ្លើយតបទៅនឹងទីតាំងដែលមានស្រាប់ ដោយក្នុងនោះមានគឺអគារ និងដើមឈើ។
- ម្លប់ដំឡើងថ្មីគឺជាគ្រោងអចិន្ត្រៃយ៍ ហើយត្រូវតែរឹងមាំ សម្រាប់ការប្រើប្រាស់រយៈពេលច្រើនឆ្នាំ។
- ការរចនាត្រូវតែដាក់ទីតាំងឆាកសម្តែងមួយសម្រាប់ព្រឹត្តិការណ៍តូចៗ និងទីតាំងឈរ ឬអង្គុយសម្រាប់ភ្ញៀវរហូតដល់១០០នាក់
- ម្លប់ដំឡើងថ្មីត្រូវតែជារចនាសម្ព័ន្ធទីតាំងដំឡើងដាច់ដោយឡែក ពោលគឺវាមិនអាចតភ្ជាប់ទៅនឹងអគារនៅទីតាំងនោះឡើយ។ ប៉ុន្តែ ការដាក់សសរជំនួយភ្ជាប់ទៅប្លង់កម្រាលគឺអាចធ្វើទៅបាន។
- ម្លប់ដំឡើងថ្មីត្រូវតែមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់រយៈពេលច្រើនឆ្នាំ ពោលគឺធន់នឹងខ្យល់ ភ្លៀង ពន្លឺព្រះអាទិត្យ និងផ្លែស្វាយជ្រុះ។
- មិនតម្រូវឱ្យមានការពារពីការជ្រាបទឹកឡើយ!

**ជួបជាមួយគណៈវិនិច្ឆ័យ**

១. លោក ងួន ឃុន កុលកតិកា, សហគ្រិន ស្ថាបត្យករ សិល្បករ, Kolkateka Architecture Atelier
២. លោក ផល ពិសិដ្ឋ , ស្ថាបត្យករ និងជាអនុប្រធានការិយាល័យស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ និងនវានុវត្តន៍, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៣. អ៊ីរ៉ង់ ទីហ្វ៊ីយ៉ានែល, Architect and Partner, Asma Architects
៤. លោក ដានីញ៉ែល ឆារស៍ នាយកគ្រប់គ្រងផ្នែកគម្រោងអភិវឌ្ឍន៍ Urban Living Solutions
៥. លោកស្រី គួន ម៉ានិត, ប្រធានគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ អង្គការសិល្បៈខ្មែរអមតៈ
៦. លោកស្រី ដាណា ឡេងល័ស នាយិកាគ្រប់គ្រងផ្នែកសិល្បៈ/ស្ថាបនិក ជំនាន់នៃភាពច្នៃប្រឌិត

**ដំណើរការដាក់ពាក្យ៖**

**ថ្ងៃផុតកំណត់ទទួលពាក្យ៖** ក្រុមរចនាត្រូវបញ្ជូនគំនិតរចនាទាំងស្រុងរបស់ខ្លួននៅត្រឹមថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២៤។ រាល់ពាក្យស្នើសុំដែលបញ្ជូនមកនៅក្រោយម៉ោង ១២ ព្រឹក នៅថ្ងៃទី១ ខែកញ្ញា នឹងត្រូវបានចាត់ទុកជាមោឃៈដោយស្វ័យប្រវត្តិ។

**ការសម្រិតសម្រាំងក្រុមជាប់ជម្រើស ៥ ចុងក្រោយ៖** ក្រោយពិនិត្យលើពាក្យដែលបានបញ្ជូនមក គណៈវិនិច្ឆ័យនឹងសម្រិតសម្រាំងជ្រើសរើសយក ៥ក្រុម ចុងក្រោយ។ ក្រុមទាំងនោះនឹងប្រកាស នៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០២៤ ហើយក្រុមនីមួយៗនឹងទទួលបានរង្វាន់ទឹកប្រាក់ចំនួន ២៥០ ដុល្លារ។

**ការបញ្ជូនពាក្យសម្រេច៖** ក្រុមរចនាទាំង៥ ក្រុម នឹងទទួលបានមតិកែលម្អពីគណៈវិនិច្ឆ័យ និងជំនួយគាំទ្រពីគ្រូបង្វឹករបស់ពួកគេ ដើម្បីអភិវឌ្ឍ និងបញ្ជូនគម្រោងសម្រេច (Master Plan) របស់ខ្លួន។ បន្ទាប់មក ក្រុមនីមួយៗនឹងធ្វើបទបង្ហាញពីគម្រោងសម្រេចរបស់ខ្លួនទៅកាន់គណៈវិនិច្ឆ័យដោយផ្ទាល់ នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០២៤។

**ការប្រកាសលទ្ធផលជ័យលាភី៖** គណៈវិនិច្ឆ័យនឹងជ្រើសរើសក្រុមរចនាជ័យលាភីមួយក្រុម ក្នុងចំណោមក្រុមទាំងប្រាំ ដោយផ្អែកលើបទបង្ហាញរបស់ពួកគេ។ លទ្ធផលនឹងចេញផ្សាយថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២៤ ហើយក្រុមជ័យលាភីនឹងទទួលបានរង្វាន់ទឹកប្រាក់ចំនួន ៧៥០ ដុល្លារ។

**តារាងពេលវេលា និងកាលបរិច្ឆេទសំខាន់ៗ៖**

| **កាលបរិច្ឆេទ** | **សកម្មភាព** | **ទីតាំង** |
|---|---|---|
| **២ កក្កដា** | **ការប្រកាសបើកពាក្យស្នើសុំ** | អនឡាញ |
| **៦ កក្កដា** | **បទបង្ហាញអំពីពាក្យស្នើសុំ និងការទស្សនាទីតាំង** | អង្គការសិល្បៈខ្មែរអមតៈ |
| **២០ កក្កដា** | **សិក្ខាសាលា៖ «ការរចនាលើការចូលរួមរបស់សហគមន៍»**<br><br>សិក្ខាសាលាឥតគិតថ្លៃនឹងបើកជូនបេក្ខជនដាក់ពាក្យទាំងអស់ ដើម្បីរៀនសូត្រពីគ្រូបង្វឹក អំពី | អង្គការសិល្បៈខ្មែរអមតៈ |

| | | |
|---|---|---|
| | និយមន័យនៃការចូលរួមរបស់សហគមន៍ និងវិធីសាស្ត្រលាយបញ្ចូលធាតុផ្សំនៃការចូលរួមរបស់សហគមន៍ទៅក្នុងការរចនារបស់ពួកគេដោយជោគជ័យ។ | |
| **៣១ សីហា** | **ថ្ងៃផុតកំណត់ទទួលពាក្យ** (រហូតដល់ម៉ោង ១១:៥៩ នាទី យប់) | អនឡាញ |
| **៦ កញ្ញា** | **ការប្រកាសលទ្ធផលក្រុមជាប់ជម្រើស ៥ ចុងក្រោយ**<br><br>ក្រុមជាប់ជម្រើស៥ចុងក្រោយនឹងទទួលការជូនដំណឹង និងអញ្ជើញមកអង្គការសិល្បៈខ្មែរអមតៈ ដើម្បីទទួលរង្វាន់ទឹកប្រាក់ និងថតរូបសម្រាប់ការផ្សព្វផ្សាយជាសាធារណៈ។ | អង្គការសិល្បៈខ្មែរអមតៈ |
| **២៨ កញ្ញា** | **បទបង្ហាញ «គម្រោងសម្រេច» ដោយក្រុមជាប់ជម្រើសទាំង ៥** | អង្គការសិល្បៈខ្មែរអមតៈ |
| **៣០ កញ្ញា** | **ការប្រកាសលទ្ធផលជ័យលាភី** | អង្គការសិល្បៈខ្មែរអមតៈ |

## នរណាអាចដាក់ពាក្យបាន?

រាល់បេក្ខជនដាក់ពាក្យទាំងអស់ត្រូវបំពេញលក្ខខណ្ឌតម្រូវខាងក្រោមនេះ៖

- ជាសិស្ស ឬជាអ្នកអាជីពក្នុងផ្នែកសិល្បៈ រចនា ឬស្ថាបត្យកម្ម
- មានសញ្ជាតិកម្ពុជា
- មានអាយុចន្លោះពី ១៨ ដល់៣០ ឆ្នាំ
- ជាក្រុមដែលមានសមាជិកយ៉ាងហោចណាស់២នាក់

## របៀបបញ្ជូនពាក្យ

បំពេញទម្រង់ខាងក្រោមក្នុងទំហំ A3 ហើយផ្ញើជាPDF ទៅកាន់ hello@javacreativecafe.com ។ អាចសរសេរពាក្យជាភាសាខ្មែរ ឬភាសាអង់គ្លេស។

១. ទំព័រមុខ
   ក. សូមបំពេញចំណុចខាងក្រោមសម្រាប់សមាជិកក្រុមនីមួយៗ៖
      I. ឈ្មោះ
      II. អាយុ
      III. ទំនាក់ទំនង
      IV. ការសិក្សា ឬការងារបច្ចុប្បន្ន
   ខ. បរិយាយគម្រោង (២០០ ទៅ៥០០ ពាក្យ)
   គ. សេចក្តីពន្យល់ថា តើគម្រោងរបស់អ្នករំលេចពីធាតុផ្សំនៃការចូលរួមរបស់សហគមន៍ដោយរបៀបណា (២០០ ទៅ៥០០ ពាក្យ)

២. រចនាគោលគំនិត រួមមាន៖
   ក. រូបភាពយោង/ផ្ទាំងរូបសម្រេច រួមទាំងសម្ភារៈដែលនឹងត្រូវប្រើ (១-២ ទំព័រ)
   ខ. ប្លង់មេ (មាត្រដ្ឋាន ១/១០០) (១ ទំព័រ)
   គ. ប្លង់ពុះ (១/១០០) (១ ទំព័រ)

ឃ. គំនូរព្រាង (ឬរូបបែប 3D) (១-៣ ទំព័រ)
ឃ. រូបសំណាក(ម៉ាកែត) ( ជម្រើស)

<u>ប្រសិនបើក្រុមរបស់អ្នកត្រូវបានជ្រើសរើសជាក្រុមមួយក្នុងចំណោមក្រុមជាប់ជម្រើសទាំង ៥ អ្នកត្រូវធ្វើបទបង្ហាញអំពីពាក្យស្នើសម្រេច ទៅកាន់គណៈវិនិច្ឆ័យនៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០២៤។ ពាក្យស្នើសម្រេចរបស់អ្នកត្រូវភ្ជាប់មកជាមួយគម្រោងសម្រេច (Master Plan ) ដែលបង្ហាញពីចំណុចខាងក្រោម៖</u>

១. គំនិតរចនាសម្រេច
២. ទិដ្ឋភាពសំខាន់ៗ (ប្លង់មេ ប្លង់ពុះ ។ល។)
៣. គម្រោងរំលេចពីការចូលរួមរបស់សហគមន៍
៤. សម្ភារៈ និងប្រភពនានា
៥. ចំណុចលម្អិតនានានៃការសាងសង់ដំឡើង

សម្រាប់សំណួរផ្សេងៗ សូមទាក់ទងទៅកាន់ hello@javacreativecafe.com ឬផ្ញើសារទៅកាន់ https://www.facebook.com/creativegeneration.art

***
«ម្លប់សហគមន៍» គឺជាកម្មវិធីមួយដែលបង្កើត និងរចនាដោយ ជំនាន់នៃភាពច្នៃប្រឌិត ហើយដំណើរការទៅបានក្រោមកិច្ចសហការជាមួយអង្គការសិល្បៈខ្មែរអមតៈ។

គម្រោងនេះអាចដំណើរការបាន ក្រោមការឧបត្ថម្ភដ៏សប្បុរសរបស់ម្ចាស់ជំនួយ Debra Fram + Eric Schwartz ។

រួមជាមួយនឹងជំនួយគាំទ្របន្ថែមពី Urban Living Solutions។